អន្តរប៊ូរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ខ្មែរឈ្នះថៃដោយកម្លាំងច្បាប់

www.hoksavann.org

ថ្ងៃទី១៩ កុម្ភៈ ២០១១



ការវិវាទរវាងខ្មែរជាមួយថៃស្តីអំពីបញ្ហាប្រាសាទព្រះវិហារ និងដីក្បែរប្រាសាទព្រះវិហារ ខ្មែរអាចមានជ័យជំនះដោយសន្តិវិធី ទៅលើការឈ្លានពានរបស់ថៃ បើអ្នកដឹកនាំខ្មែរបច្ចុប្បន្នប្រើវិចារណញ្ញាណព្យាយាមប្រមូលកម្លាំងខ្មែរគ្រប់ផ្នែក ជៀសវាងទំនាស់ខ្មែរគ្នាឯង ។ នៅពេលនេះ ពុំមានខ្មែរណារត់ចូលសត្រូវ រួមកម្លាំងជាមួយសត្រូវមកវាយប្រហារខ្មែរស្នេហាជាតិឡើយ ។ កាលជំនាន់ដើម តាមប្រវត្តិសាស្ត្រ ពួកខ្មាំងសត្រូវបានបំបែកបំបាក់ខ្មែរឲ្យបែកគ្នាឲ្យរួមកម្លាំងជាមួយខ្លួនមកវាយខ្មែរ ។ នៅសតវត្សរ៍ទី២០ និងទី២១នេះ អង្គការសហប្រជាជាតិមានច្បាប់ទម្លាប់ទប់ទល់មិនឲ្យប្រទេសមួយទៅឈ្លានពានប្រទេសមួយទៀតឡើយ ។ ប៉ុន្តែទោះបីមានច្បាប់ទម្លាប់ហើយក៏ដោយ បើខ្មែរមិនចេះធ្វើការ គ្មានអ្នកចេះដឹងអ្នកជំនាញការរត់ការខាងផ្លូវច្បាប់ទេ ពុំមានជោគជ័យឡើយ ព្រោះមនុស្សក្នុងលោកមានបក្សមានពួកកាន់ជើងគ្នាទៅវិញទៅមក ពិបាករកយុត្តិធម៌ណាស់ ដូចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិប្រជុំគ្នានៅថ្ងៃទី១៤ កុម្ភៈ ២០១១ ស្តីអំពីបញ្ហាប្រាសាទព្រះវិហារ មិនហ៊ានថ្កោលទោសថៃដែលបាញ់ផ្លោងគ្រាប់បែក ធ្វើឲ្យខូចខាតប្រាសាទព្រះវិហាររបស់ខ្មែរដែលជាបេតិកភ័ណ្ឌពិភពលោកឡើយ បានរុញរឿងនេះឲ្យសមាគមអាស៊ានដោះស្រាយ ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ សម័យនេះជាពេលវេលាគោរពច្បាប់ ។ កាលពីសម័យបុព្វកាល ជាពិសេសមុនសង្គ្រាមលោក ពិភពលោកពុំទាន់មានច្បាប់សំរាប់គ្រប់គ្រងសង្គមមនុស្សនៅឡើយ គេឈ្នះចាញ់គ្នាដោយប្រើកម្លាំងយុទ្ធវិធី ឬហៅម៉្យាងទៀតដោយកម្លាំងបាយ ។ ក្នុងន័យនេះហើយ បានជារាជាណាចក្រកម្ពុជាពីដើមមានទឹកដីធំទូលំទូលាយ ជាមហាអំណាច ឥឡូវនៅរួមតូចដូចសព្វថ្ងៃ ដោយការបែកបាក់សាមគ្គីគ្នា មានសង្គ្រាមផ្ទៃក្នុង ជាឱកាសល្អរបស់ប្រទេសជិតខាង ដែលចង់បានទឹកដីខ្មែរវាយលុកចូលមកប្រទេសកម្ពុជា រំលោភយកទឹកដីខ្មែរបន្តិចម្តងៗ ។

សម័យមានច្បាប់ទម្លាប់នេះ ដើម្បីការពារឯករាជ្យ អធិបតេយ្យជាតិ និងបូរណភាពទឹកដី គេរៀបចំកម្លាំងនយោបាយ កម្លាំងកងទ័ព និងកម្លាំងសេដ្ឋកិច្ចឲ្យដើរទៅជាមួយគ្នា ។ ចំពោះព្រះពុទ្ធសាសនា ទោះបីព្រះអង្គប្រៀនប្រដៅមនុស្សលោកកុំឲ្យប្រើអំពើហិង្សា កុំធ្វើសង្គ្រាម ក៏ព្រះអង្គមិនបានហាមប្រទេសដែលគេរៀបចំកងទ័ពដើម្បីការពារប្រទេសរបស់គេទប់ទល់ នឹងសត្រូវឈ្លានពានឡើយ ។ បានសេចក្តីថា ព្រះអង្គបានពន្យល់កុំឲ្យមនុស្សបៀតបៀនគ្នា រំលោភលើគ្នា ពាក្យនេះជាឫសគល់នៃសិទ្ធិមនុស្ស ព្រោះសេចក្តីសុខសន្តិភាពកើតពីការមិនបៀតបៀនគ្នាវិញទេ ។ បើមានបញ្ហាត្រូវជួបចរចាគ្នាដោយសន្តិវិធី កុំធ្វើសង្គ្រាម ព្រោះសង្គ្រាមនាំឲ្យអន្តរាយទាំងសងខាង ទាំងជីវិតមនុស្សទាំងសម្បត្តិរបស់ជាតិ ជាពិសេសនាំឲ្យប្រជាពលរដ្ឋរងទុក្ខវេទនា ។ ក្នុងន័យនេះ ប្រទេសថៃជាប្រទេសគោរពព្រះពុទ្ធសាសនាដូចប្រទេសកម្ពុជា ដែលបែរជាអ្នកដឹកនាំថៃមានចិត្តអាក្រក់ ចេះតែឈ្លានពានរំលោភយកទឹកដីខ្មែរមិនចេះចប់ ផ្ទុយពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ អំពើបាបកម្មរបស់ថៃ ដែលបានសាងមកលើជនជាតិដទៃ ជាពិសេសមកលើកម្ពុជា ថៃនឹងត្រូវទទួលរងទុក្ខវេទនាវិញពុំខានឡើយ ។ ថៃជាជនជាតិអកត្តញ្ញូរមិលគុណ ព្រោះចំណេះដឹងវប្បធម៌ស្ទើរតែគ្រប់ផ្នែក មានអក្សរសាស្ត្រជាដើម ចម្លងពីខ្មែរជាគ្រូ តែកូនសិស្សនេះទៅជាប្រមាថមើលងាយគ្រូ នៅពេលដែលគ្រូចុះទន់ខ្សោយ ។ យើងពោលនេះចំពោះទៅថៃ ដែលមានចិត្តអាក្រក់ ជាពិសេសថៃអ្នកដឹកនាំ ចំណែកប្រជាពលរដ្ឋថៃយើងយល់ថា នៅមានចិត្តល្អជាមួយខ្មែរ ។ មួយទៀតប្រទេសជិតខាងគ្នា ពុំអាចយកគ្នាជាសត្រូវរហូតឡើយ ត្រូវតែរស់នៅជាប្រទេសភូមិផងរបងជាមួយដោយសុខសាន្តនឹងគ្នា ។

បើមកពិនិត្យមើលសមាគមអាស៊ីភាគអាគ្នេយ៍ តើសមាគមនេះមានឥទ្ធិពលមានអំណាចគ្រប់គ្រាន់ អាចជួយដោះស្រាយបញ្ហាវិវាទរវាងខ្មែរនិងថៃបានកម្រិតណា ? តាមពិនិត្យមើល សមាគមនេះពុំទាន់មានស្នាដៃបែបណាមួយជួយដោះស្រាយជម្លោះក្នុងតំបន់នៅឡើយ ។ តាមយើងយល់ សមាគមនេះអាចជួយកុំឲ្យខ្មែរនិងថៃច្បាំងគ្នាតទៅទៀត ហើយជួយជាអាជ្ញាកណ្តាលនៅពេលខ្មែរថៃចរចាត្រង់ដីមានជម្លោះ ។

ខ្មែរត្រូវប្តឹងទៅតុលាការក្រុងឡាអេប្រទេសហូឡង់ សុំឲ្យគេបកស្រាយសាលក្រមតុលាការឆ្នាំ១៩៦២ ដែលកាត់ឲ្យខ្មែរឈ្នះក្តីព្រះវិហារ ពុំមែនកាត់ក្តីឡើងវិញទេ គឺបកស្រាយសាលក្រមដែលកាត់សេចក្តីរួចហើយ ។ គំនិតនេះតាមដំណឹងថា រាជរដ្ឋាភិបាលខ្មែរបានគិតគូររួចអស់ហើយ ។ លើសពីនេះទៀត រាជរដ្ឋាភិបាលខ្មែរគួរប្តឹងថៃអំពីការដែលថៃបានបាញ់ផ្លោង គ្រាប់បែកធ្វើឲ្យខូចខាតប្រាសាទព្រះវិហារ និងការប្រើប្រាស់គ្រាប់បែកចង្កោម ។ ក្រៅពីនេះ ត្រូវអំពាវនាវឲ្យអង្គការយូណេស្កូ មកពិនិត្យមើលការខូចខាតព្រះវិហារ ទោះបីថៃជំទាស់ក៏ដោយ ។៚

*　*

*

ប្រ

☆ ☆

☆